អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន
# អង្គបុរេជំនុំជម្រះបង្គាប់ឲ្យបោះពុម្ពផ្សាយដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១

ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានចេញសេចក្តីសម្រេចចំនួនពីរ ដែលក្នុងនោះ បានបង្គាប់ឲ្យបោះពុម្ពផ្សាយនូវឯកសារនានាពាក់ព័ន្ធនឹងសំណុំរឿង ០០៤/១។ ជាពិសេស អង្គបុរេជំនុំជម្រះបង្គាប់ឲ្យបោះពុម្ពផ្សាយទាំងស្រុងនូវសំអាងហេតុនៃដីកាដំណោះស្រាយ ដែលបានលើកលែងការចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងនឹង អ៊ឹម ចែម។

ឯកសារនេះនឹងអាចរកមើលបានទាំងស្រុងតែម្តង ដោយត្រូវស្ថិតក្រោមវិធានការការពារសាក្សី។

អង្គបុរេជំនុំជម្រះក៏បានសម្រេចផងដែរឲ្យបោះពុម្ពផ្សាយនូវដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ព្រមទាំងចម្លើយតបរបស់សហមេធាវីការពារក្តី និង ឯកសារផ្សេងៗជាច្រើនទៀត ក្នុងនោះរួមមាន ប្រតិចារឹកសវនាការ ថ្ងៃទី ១១ និង ១២ ខែ ធ្នូ ឆ្នាំ ២០១៧។

អង្គបុរេជំនុំជម្រះទទួលបានបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ក្នុងសំណុំរឿងនេះហើយ។ អង្គបុរេជំនុំជម្រះនឹងចេញសាលដីការបស់ខ្លួននាពេលឆាប់ៗនេះ។

សេចក្តីសម្រេចទាំងពីរទាក់ទិននឹងការបោះពុម្ពផ្សាយដីកាដំណោះស្រាយ និងឯកសារពាក់ព័ន្ធក្នុងសំណុំរឿង០០៤/១ នេះ អាចរកមើលបាននៅក្នុងគេហទំព័ររបស់ អ.វ.ត.ក៖

https://eccc.gov.kh/km/document/court/secktiismrecloesmnnoerps-qym-caem
https://eccc.gov.kh/km/document/court/secktiismrecloesmnnoerps-qym-caem-0

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦
ទូរស័ព្ទលើតុ: +៨៥៥(0)២៣៨៦១៥៦៤
អ៊ីម៉ែល: neth.pheaktra@eccc.gov.kh